ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៩៤៦ សហវ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ១១ ឆ្នាំ ២០០២

# ប្រកាស
## ស្តីពី
## ការបំពេញបន្ថែមគណនីក្នុងប្លង់គណនេយ្យរដ្ឋ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ដែលប្រកាស អោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម /១២០១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០១ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០០/០២ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាស អោយប្រើច្បាប់ស្តីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ/បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជា ទូទៅនៃ គណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អ.ន.ក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញប្រកាសលេខ ០០៩ ប្រក.សហវ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីប្រព័ន្ធគណនីរបស់រតនាគារជាតិ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**ប្រការ ១** : ត្រូវបានបំពេញបន្ថែមនៅក្នុងប្រព័ន្ធគណនីនៃគណនេយ្យរដ្ឋនូវគណនីដែលមានឈ្មោះ និង លេខសំគាល់ដូចខាងក្រោមនេះ :

គណនី " តំលៃសញ្ញាបណ្ណ័រដ្ឋដែលបានតំកល់ទុកនៅរតនាគារជាតិ " លេខគណនី ៥១១ " ។

គណនីលេខ ៥១១ ប្រើប្រាស់សំរាប់កត់ត្រាតាមដាននូវតំលៃនៃសញ្ញាបណ្ណ័រដ្ឋដែលបានតំកល់ទុកនៅរតនាគារជាតិដើម្បីបំពេញលក្ខខណ្ឌធានាសកម្មភាពអាជីវកម្ម សេវាកម្មហិរញ្ញវត្ថុរបស់អង្គភាពរដ្ឋ ។

**ប្រការ ២** : ប្រព្រឹត្តិកម្មនៃគណនី :

ខ្លឹមសារនៃគណនីនេះត្រូវបានកត់ត្រា :

**ឥណពន្ធ** : កត់ត្រាតំលៃនៃសញ្ញាប័ណ្ណរដ្ឋ ដែលបានតំកល់ទុកនៅរតនាគារជាតិដើម្បីជាការធានាសកម្មភាពអាជីវកម្ម ។

**ឥណទាន** : កត់ត្រាតំលៃនៃសញ្ញាប័ណ្ណរដ្ឋដែលបានបញ្ចេញដោយលក់ ដោយអនុប្បទាន ជំរះឬបន្ថយពីការតំកល់ទុកនៅរតនាគារជាតិ ។

**សមតុល្យ** : ឥណាយិកឆ្លុះបញ្ចាំងតំលៃសញ្ញាប័ណ្ណរដ្ឋដែលកំពុងតំកល់ទុកនៅរតនាគារជាតិ ។

គណនី "តំលៃនៃសញ្ញាប័ណ្ណរដ្ឋដែលបានតំកល់ទុកនៅរតនាគារជាតិ" អាចបើកជាអនុគណនីដើម្បីធ្វើការតាមដានជាលំអិតនូវតំលៃសញ្ញាប័ណ្ណរដ្ឋទៅតាមប្រភេទនិមួយៗ ។

**ប្រការ ៣** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

***កន្លែងទទួល*** :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៣
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ